ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៣០/២៧-១-២០០៩

សាលដីកា

លេខ:៣៧ក្រVអ/៣-៥-២០១១

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី៣-៥-២០១១ ដែលមានសមាសភាពដូចតទៅ :

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៣០ ចុះថ្ងៃទី២៧-១-២០០៩ រវាង :

-ជនជាប់ចោទឈ្មោះ [redacted] សុខឡេង ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរសន្តិសុខក្រុមហ៊ុន ស៊ី អេ អេស កើតនៅភូមិ[redacted] ទីលំនៅសព្វថ្ងៃភូមិ[redacted] ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០១នាក់ ទោសពីមុនគ្មាន ជា ¨ដើមបណ្តឹងឧទ្ធរណ៍¨ ។

ចាប់ខ្លួនថ្ងៃទី០២-១២-២០០៧ ឃុំខ្លួនថ្ងៃទី០២-១២-២០០៧

មេធាវីការពារលោក [redacted] ចន្ថា

ត្រូវចោទពីបទៈរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិត្រពាំងទូល ឃុំកំបូល ស្រុកកំបូល ខេត្តកណ្តាល កាលពីថ្ងៃទី០១-១២-២០០៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ជនរងគ្រោះឈ្មោះ [redacted] សំអាន ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរអ្នករត់តុនៅក្នុងហាង ទីលំនៅសព្វថ្ងៃ [redacted] ។

**ឯរឿងហេតុមានដូចតទៅ**

តាមពាក្យបណ្តឹងចុះថ្ងៃទី០១-១២-២០០៧ របស់ឈ្មោះ [redacted] **សំអាន** បានប្តឹងឈ្មោះ [redacted] **សុខឡេង** ស្នាក់នៅភូមិ [redacted] ដោយកាលពីថ្ងៃទី០១-១២-២០០៧ វេលាម៉ោង ២០នាទីយប់ ខ្លួនបានមករកប្តីខ្លួនឈ្មោះ [redacted] **ផយ** ដែលធ្វើការក្នុងរោងចក្រ [redacted] **អាប់** ក្នុងភូមិត្រពាំងទូល ឃុំដំបូក បានជួបនឹងឈ្មោះ [redacted] **សុខឡេង** ជាសន្តិសុខ ខ្លួនក៏បានសួរគាត់ថា មានម៉ូតូឌុបទេ គាត់ឆ្លើយថាគ្មានទេ រួចគាត់ក៏ទាញខ្លួនទៅក្រោយរួចក៏ចាប់រំលោភខ្លួនជាបន្តបន្ទាប់ រហូតបានសំរេចចំនួន២លើក ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុខឡេង** ឆ្លើយថា: កាលពីថ្ងៃទី០១-១២-២០០៧ វេលាម៉ោង ៧:៣០នាទី ខ្លួនស្រឡាញ់ឈ្មោះ [redacted] **សំអាន** ពីមុនមិនដែលស្គាល់គ្នាទេ ហើយក៏ត្រូវគ្នារួមភេទបាន២ដង គេទារលុយ១០០០០រៀល ខ្លួនគ្មានលុយក៏គេប្តឹងតែម្តង ។ ខ្លួនបបួលគេមុនទៅចូលដេក ខ្លួនមិនបានបង្ខំគេទេ សមត្ថកិច្ចឃាត់ខ្លួននៅយប់នោះតែម្តង ខ្លួនយាមប៉ុស្តិ៍សន្តិសុខក្រុមហ៊ុន ខ្លួនឱ្យគេដេកមួយយប់ទល់ភ្លឺតែគេមិនព្រម គេក៏ចុះមកជួបប្តីគេទៅ ខ្លួនមិនបានដឹងនារីនោះមានប្តីនៅទីនោះទេ ខ្លួនដឹងថានារីនោះរកស៊ីផ្លូវភេទ គេទារលុយតែខ្លួនគ្មានលុយ ។ ខ្លួននៅជាមួយនារីនោះមិនបានបង្ខិតបង្ខំគេទេ ខ្លួនមិនបាននិយាយរឿងលុយកាក់ទេ ។

-តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] **សំអាន** ឆ្លើយថា: ខ្លួនមិនចេះអក្សរទេ ខ្លួនទៅពីភ្នំពេញទៅជួបប្តីនៅរោងចក្រ ហើយពេលល្ងាចឈ្មោះ [redacted] **សុខឡេង** ក៏ចាប់រំលោភខ្លួនតែម្តង ។ ខ្លួនត្រូវបានគេបង្ខំឱ្យរួមភេទដោយគេក្តោបមាត់កុំឱ្យស្រែក គេរួមភេទខ្លួនបានពីរដង ។ នៅពេលគេចាប់នោះពុំមានអ្នកណាឃើញទេ ។ ពេលខ្លួនជួបបុរសនោះ ពុំមានអ្នកណានៅជិតខ្លួនទេ គឺរំលោភនៅជាន់ទី៣ រំលោភបាន២ដង ខ្លួនស្រែកដែរតែគ្មានអ្នកណាលឺទេ ។ ខ្លួនមកពីភ្នំពេញជួបប្តីខ្លួន ហើយក៏ត្រឡប់ទៅភ្នំពេញវិញ ដែលត្រូវគេរំលោភខ្លួនតែម្តងទៅ ។ ខ្លួនឈប់ប្តឹង ខ្លួនពុំទារជម្ងឺចិត្តទេ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ:៣៤(ប) ចុះថ្ងៃទី៣-១២-២០០៨ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-ផ្តន្ទាទោស:

-ឈ្មោះ [redacted] **សុខឡេង** (សាវតាជាតិមាននៅក្នុងសំណុំរឿងស្រាប់) ដាក់ពន្ធនាគារកំណត់រយ:ពេល ១០ឆ្នាំ(ដប់ឆ្នាំ) ពីបទ:រំលោភសេពសន្ថវ: ប្រព្រឹត្តនៅភូមិត្រពាំងទូល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០១-១២-២០០៧ តាមបញ្ញត្តិមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណ: នៅចំពោះមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិឱ្យប្តឹងតវ៉ា នៅក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី១៥-២-២០១០ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

<u>នាពេលសវនាការ</u>

-ប្រធានក្រុមប្រឹក្សាសង្ខេបរឿង

-ជនជាប់ចោទឈ្មោះ [redacted] **សុខឡេង** ( អវត្តមាន)

.-ជនរងគ្រោះឈ្មោះ [redacted] **សំអាន** ( អវត្តមាន)

-តំណាងមហាអយ្យការសន្និដ្ឋានថា: ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣-១២-២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] **សុខឡេង** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៣០ ចុះថ្ងៃទី៣-១២-២០០៨ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការ ។

-មេធាវីការពារលោក [redacted] **ចន្ថា** សន្និដ្ឋានថា: ឆ្លងតាមរបាយការណ៍ និង សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ កូនក្ដីខ្លួនកន្លងមកធ្លាប់បានស្រលាញ់ជនរងគ្រោះ ហើយបានរួមភេទជាមួយជនរងគ្រោះចំនួន២ដង ហើយជនរងគ្រោះបានដកពាក្យបណ្ដឹងរួចហើយ សូមក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់កូនក្ដីខ្ញុំដោយអនុគ្រោះ ។

-ក្រោយពីបានអានរបាយការណ៍

-ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹង

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សាលាឧទ្ធរណ៍</u>

<u>យល់ឃើញថា</u> :

១-បណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣-១២-២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] **សុខឡេង** ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-មេធាវី [redacted] **ចន្ថា** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣-ចម្លើយជនជាប់ចោទ [redacted] **សុខឡេង** បានឆ្លើយថា កាលពីថ្ងៃទី១-១២-២០០៧ ម៉ោង២០ម៉ បានរួមភេទជាមួយនារី [redacted] **សំអាន** បាន២ដង ដោយការព្រមព្រៀង គេទារលុយ១០០០០៛ តែគ្មានប្រាក់ឱ្យទើបគេប្ដឹង។

៤-តាមចម្លើយរបស់ឈ្មោះ [redacted] **សំអាន** ថា ពេលខ្លួនទៅជួបប្ដី ហើយត្រឡប់មកវិញរកម៉ូតូឌុប ជួបសន្តិសុខម្នាក់ ក៏ចាប់ទាញដៃខ្លួនចូលទៅក្នុងរោងចក្រ ហើយខ្ទប់មាត់ និង រំលោភបានសំរេចចំនួន២ដងមែន ។ ក្រោយមកខ្លួនបានមកជួបប្ដី ហើយប្រាប់ថាឈ្មោះ [redacted] **សុខឡេង** រំលោភខ្លួន ។

៥-សាលក្រមព្រហ្មទណ្ឌលេខ:៣០ ចុះថ្ងៃទី៣-១២-២០០៨ របស់សាលាដំបូងខេត្តកណ្ដាល មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី៣-១២-២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] **សុខឡេង** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:៣០ ចុះថ្ងៃទី៣-១២-២០០៨ របស់សាលាដំបូងខេត្តកណ្ដាល ទុកជា បានការ ។

៣-ឱ្យបន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៤-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវី [redacted] ចន្ថា ការពារសិទ្ធិឱ្យជនជាប់ចោទ, កំបាំងមុខជនជាប់ចោទ និង ដើមបណ្ដឹង ។

បើកផ្លូវតវ៉ា តាមកំណត់ច្បាប់ ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះ អោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ១៣ ខែ ០១ ឆ្នាំ ២០១៥

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]



៤២